ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥-០១០-១៤៧ប្រ.ក

# ប្រកាស
## ស្តីពី
## ការបង្កើតសភាផាត់ទាត់មូលប្បទានប័ត្រជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក នៅសាខាធនាគារជាតិនៃកម្ពុជា ខេត្តបាត់ដំបង

* * * * * * * * * * * * * * * *

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ: នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ: នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការៀបចំ និងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ: នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខ: ធ៥.០០-១៥០ប្រក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់ដុល្លារអាមេរិក
- បានឃើញប្រកាសលេខ: ធ៥.០០-១៧០ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០០ ស្តីពីសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល
- បានឃើញប្រកាសលេខ: ធ៨.០២-១៧៩ប្រ.ក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០២ ស្តីពីការបង្កើតសាខាធនាគារជាតិនៃកម្ពុជាខេត្តបាត់ដំបង
- តាមសំណើរបស់អគ្គនាយកដ្ឋាន ធនាគារជាតិនៃកម្ពុជា

## សំរេច

**ប្រការ ១.-**

បង្កើតសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក នៅសាខាធនាគារជាតិនៃកម្ពុជាខេត្តបាត់ដំបង ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ២.-**

សភាផាត់ទាត់សាខាធនាគារជាតិនៃកម្ពុជាខេត្តបាត់ដំបង មានភារកិច្ចអនុវត្តតាមខ្លឹមសារនៃប្រកាសលេខ: ធ ៥០០-១៥០ប្រ.ក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០០ ស្តីពីសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់ដុល្លារអាមេរិក និងប្រកាសលេខ: ធ៥០០-១៧០ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០០ ស្តីពីសភាផាត់ទាត់មូលប្បទានប័ត្រចារឹកជាប្រាក់រៀល ។

**ប្រការ៣.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ៤.-**

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

ភ្នំពេញ, ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០
**ទេសាភិបាល**

**ជា-ចាន់តូ**

**កន្លែងទទួល** :
- ដូចប្រការ៣ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចំលងជូន** :
- អភិបាលខេត្តបាត់ដំបង
- គ្រប់ធនាគារសមាជិកសភាផាត់ទាត់

"ដើម្បីជ្រាប និងផ្តល់កិច្ចសហការ"